## ខ្លឹមសារសង្ខេបសាលដីកាតុលាការកំពូលលេខ២៥៦(២០១៣) បង្ករបួសស្នាមដោយចេតនា

**ពាក្យគន្លឹះ៖** បទបង្ករបួសស្នាម, ធាតុផ្សំនីត្យានុកូលភាព, សំអាងហេតុគ្រប់គ្រាន់, ការបកស្រាយច្បាប់តឹងរឹង

### ១.អង្គហេតុនិងប្រវត្តិនីតិវិធី

កាលពីថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០០៤ ក្នុងភូមិចំការចេក ស្រុកបាត់ដំបង មានការបង្ករបួសស្នាម បង្កដោយមនុស្ស១០រូប (វាយគ្នាទៅវិញទៅមក)។ អង្គហេតុនេះ ត្រូវបានចោទជាបទបង្ករបួសស្នាមដោយចេតនាមានអាវុធ (មាត្រា៤១នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល) លើជនជាប់ចោទ៥រូប និងបង្ករបួសស្នាមដោយចេតនាមានអាវុធ និងជេរប្រមាថ (មាត្រា៤១និង៦៣នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និងមាត្រា៨នៃច្បាប់ស្ថានទម្ងន់ទោស) ចំនួន៥រូប (ម្នាក់អាយុ១៧ឆ្នាំ)។ សាលាដំបូងខេត្តបាត់ដំបង តាមសាលក្រមលេខ៤៩២(ឃ) មេសាឆ្នាំ២០០៧ បានសម្រេចឲ្យជនជាប់ចោទប្រាំរូបរួចផុតពីបទជេរប្រមាថ និងដាក់ទោសលើជនជាប់ចោទចំនួន៥នាក់ ចន្លោះ៣ខែ ទៅ១០ខែ តាមមាត្រា៤១ និងផ្តន្ទាទោស៥រូប តាមមាត្រា៤១ មាត្រា៦៣ និងមាត្រា៨ ទោសពី៣ខែទៅ៦ខែ។ ជនជាប់ចោទតែម្នាក់ បានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសាលក្រមនេះ។ តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍អះអាងថា ទោសនេះស្រាល ដោយសារជនជាប់ចោទ ស្ថិតនៅក្នុងករណីមិនរាងចាល (ទោសជាប់ពន្ធនាគារ១០ខែ ត្រូវបានកែប្រែទៅព្យួរ)។ សាលាឧទ្ធរណ៍ ចេញសាលដីកាលេខ៦៧(ខ)ឧសភា ឆ្នាំ២០០៩ តម្កល់សាលក្រមលេខ៤៩២ ហើយជនជាប់ចោទបានប្តឹងសាទុក្ខមកតុលាការកំពូល។ តំណាងមហាអយ្យការអមតុលាការកំពូលស្នើឲ្យ បដិសេធសាលដីកាលេខ៦៧(ខ)។ តុលាការកំពូលបានបើកសវនាការក្នុងថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៣ និងចេញសាលដីកាលេខ២៥៦ ខែតុលា ឆ្នាំ២០១៣។

### ២.សំអាងហេតុនិងសេចក្តីសម្រេច

១. តុលាការកំពូលយល់ថា ការកែប្រែទោសពន្ធនាគារទៅជាទោសព្យួរ ដោយសំអាងថា ជនជាប់ចោទកំពុងអនុវត្តទោសសាកល្បង ជាសំអាងហេតុមិនគ្រប់គ្រាន់ ដោយសារមិនបានសំអាងផ្អែកលើបទប្បញ្ញត្តិព្រហ្មទណ្ឌណាមួយអនុញ្ញាតឲ្យដកហូតទោសព្យួរ៖ *តាមស្មារតីមាត្រា៣ (គោលការណ៍នីត្យានុកូលភាព) កឋាខណ្ឌទី២នៃក្រមព្រហ្មទណ្ឌចែងថា "មានតែទោសដែលមានចែងក្នុងបទបញ្ញត្តិព្រហ្មទណ្ឌជាធរមាន នៅពេលដែលបទល្មើស ត្រូវបានប្រព្រឹត្តប៉ុណ្ណោះ ទើបអាចត្រូវប្រកាសបាន" ឯមាត្រា៥នៃក្រមដដែលកំណត់ថា ការបកស្រាយច្បាប់ព្រហ្មទណ្ឌត្រូវមានភាពតឹងរ៉ឹង។ ...ដូច្នេះភាពមិនគ្រប់គ្រាន់នៃសំអាងហេតុ ចាត់ទុកថាគ្មានសំអាងហេតុ យោងតាមស្មារតីមាត្រា៤១៩ ចំណុចទី៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌដែល*

*តុលាការអង្គហេតុគប្បីពិចារណាជាថ្មី កុំឱ្យប៉ះពាល់ដល់គោលការណ៍នីត្យានុកូលភាពនៃទោសនៃច្បាប់ព្រហ្មទណ្ឌ។*

**សម្រេចៈ ២.** តម្កល់សាលដីកាលេខ១៦៧(ខ) លើកលែងចំណុចស្តីពីការដកហូតទោសព្យួរ ត្រូវបដិសេធចោទ...**៣.** បង្វិលសំណុំរឿង...ទៅឱ្យសាលាឧទ្ធរណ៍ដើម្បីជំនុំជម្រះជាថ្មី អំពីចំណុចខាងលើ។

## ៣.កំណត់សំគាល់

**១.** ក្នុងរឿងនេះ សាលាដំបូងបានកែប្រែទោសគុក ក្នុងសាលក្រមមុន មកជាទោសព្យួរ ដោយមិនបានផ្អែកតាមបទបញ្ញត្តិណាមួយ ដែលតុលាការកំពូលអះអាងថា ខ្វះសំអាងហេតុផ្លូវច្បាប់។ វាទំនងតុលាការជាន់ទាបបកស្រាយច្បាប់ទូលាយ ដែលនេះហើយ តុលាការកំពូល បានដកស្រង់ខាងលើនូវមាត្រា៥នៃក្រមព្រហ្មទណ្ឌ។

**២.** ការតម្រូវឱ្យបកស្រាយព្រហ្មទណ្ឌតឹងរឹង កុំឱ្យតុលាការបង្កើតបទល្មើសថ្មី។ មាត្រា៥ មានបំណងការពារសិទ្ធិនិងប្រយោជន៍ជនជាប់ចោទ។ ក្នុងរឿងនេះ សាលាដំបូងសម្រេចល្អៀងមកជនជាប់ចោទ ទោះបីមិនមានបទប្បញ្ញត្តិច្បាប់យកមកសំអាង។ មាត្រា៤១៩ ដោយប្រយោលទាមទារនូវសាលក្រមមានសំអាងហេតុ។ អ្វីដែលអាចរៀនសូត្របាន គឺសំអាងហេតុត្រូវតែគ្រប់គ្រាន់ ប្រសិនបើមិនដូចនេះទេ ត្រូវចាត់ថាគ្មានសំអាងហេតុ។ វត្តមានសំអាងហេតុក្នុងសាលដីកា ឬសាលក្រម នឹងបង្កភាពងាយស្រួល ដល់ជនជាប់ចោទថា គាត់គួរ ឬមិនគួរប្តឹង ដែលនេះជាសិទ្ធិប្តឹងឧទ្ធរណ៍ (មាត្រា១៤.៥ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ ឆ្នាំ១៩៦៧)។